# សុន្ទរកថាស្វាគមន៍ និងសេចក្តីរាយការណ៍
# បូកសរុបលទ្ធផលនៃអង្គសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សា
# ឃុំ សង្កាត់អាណត្តិទី២ ជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
# និងជាប្រធាន គ.ជ.អ.ប

ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១

- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តមអនុប្រធានទី២ នៃព្រឹទ្ធសភា
- ឯកឧត្តមអនុប្រធានទី២ នៃរដ្ឋសភា
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តមប្រធាន គ.ជ.ប
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកឧត្តមអគ្គរដ្ឋទូតនានាប្រចាំនៅកម្ពុជា
- ភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គសន្និបាតជាទីមេត្រី !

ជាបឋម ក្នុងនាមសមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ជាមួយនឹងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែល**សម្តេច**បានឆ្លៀតយកឱកាសដ៏មមាញឹកនៅក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់**សម្តេច**ក្នុងការដឹកនាំជាតិមាតុភូមិ អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងពិធីបិទសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ នាឱកាសដ៏មហោឡារិកអធិកអធម នេះ។ ក្នុងនាមអង្គសន្និបាតទាំងមូល ខ្ញុំសូមអនុញ្ញាតប្រសិទ្ធពរជ័យមហាប្រសើរជូន **សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូម**សម្តេច**ទទួលបានសុខភាពល្អ សិរីសួស្តី ឈ្នះអស់មារសត្រូវ និងទទួលបានមហាជោគជ័យថ្មីៗថែមទៀតក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ **សម្តេច** ក្នុងការដឹកនាំប្រទេសជាតិប្រកបដោយសន្តិភាព ស្ថេរភាព វិបុលភាព ជាមួយនឹងការអភិវឌ្ឍនៅគ្រប់ ទិសទី។

## -សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
## -ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!

អង្គសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ បានដំណើរការក្នុងរយៈពេល២ថ្ងៃ ស្របតាមកម្មវិធីដែលបានគ្រោងទុក ដោយបានការអញ្ជើញចូលរួមពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាង២០០នាក់ ដែលតំណាងឱ្យឃុំ សង្កាត់ទូទាំងប្រទេស ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន១៩៣ តំណាងឱ្យក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ក្រុមប្រឹក្សារាជធានី ខេត្តចំនួន៤៨នាក់តំណាងឱ្យរាជធានី ខេត្តទូទាំងប្រទេស និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន១០៥នាក់ ព្រមទាំងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា តំណាងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានចំនួនសរុបប្រមាណជាង៧០០នាក់។

អង្គសន្និបាតទាំងមូលបានឯកភាពខ្ពស់ចំពោះរបាយការណ៍វាយតម្លៃអំពីសមិទ្ធផលនៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ សមិទ្ធផលរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រយៈពេលជាង២ឆ្នាំ ក៏ដូចកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេលជិត១០ឆ្នាំមកនេះ។ ទន្ទឹមនេះ អង្គសន្និបាតបានធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់នូវបទពិសោធន៍នៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាមួយចំនួននៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងបទអន្តរាគមន៍របស់ស្ថាប័នសិក្សាស្រាវជ្រាវឯករាជ្យក្នុងប្រទេស ដែលបង្ហាញអំពីការរកឃើញរបស់ខ្លួនជុំវិញការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផ្អែកតាមរបាយការណ៍ និងបទអន្តរាគមន៍នានា អង្គសន្និបាតទាំងមូលបានបែងចែកក្រុមពិភាក្សាដែលប្រមូលផ្តុំលើបញ្ហាសំខាន់៧ ដែលជាតម្រូវការជាអាទិភាពក្នុងកំណែទម្រង់ ជាអាទិ៍ៈ ការប្រមើលមើលអំពីជម្រើសសមស្របនានាសម្រាប់ការបង្កើតសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ភាពចាំបាច់នៃការដាក់ឱ្យដំណើរការនូវមូលនិធិក្រុង ស្រុក ដែលតម្រូវដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការ និងវិធីសាស្ត្រនៃការគាំទ្ររបស់ខេត្តចំពោះក្រុង ស្រុក និងឃុំ សង្កាត់ក្នុងស្ថានភាពដែលប្រព័ន្ធគាំទ្រនេះ កំពុងត្រូវបានធ្វើការកែសម្រួល ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសង្គមដោយផ្តោតទៅលើជនងាយរងគ្រោះ ជនជាតិដើមភាគតិច ស្ត្រី និងកុមារ តម្រូវការចាំបាច់នៃការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងតួនាទីរបស់យុវជនក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន។

ឆ្លងតាមការពិភាក្សា អង្គសន្និបាតបានធ្វើការវាយតម្លៃខ្ពស់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានតួនាទីស្នូលក្នុងការទ្រទ្រង់ដល់ការបង្កើត និងការធ្វើឱ្យមានចិរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ អង្គសន្និបាតទាំងមូលបានប្តេជ្ញាចិត្តក្នុងការបន្តគាំទ្រក្នុងដំណើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ នាថ្ងៃអាទិត្យទី០៣ ខែមិថុនា ឆ្នាំ២០១២ខាងមុខនេះ ឱ្យប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព។

**៉សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

**៉ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក!**

តាមរយៈសន្និបាតនេះ បានបង្ហាញកាន់តែច្បាស់នូវការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំយកនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ធ្វើជាចក្ខុវិស័យក្នុងការកែលម្អរដ្ឋបាលសាធារណៈ ដើម្បីគាំទ្រដល់កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។ សមិទ្ធផលលើវិស័យជាច្រើនដែលសម្រេចបានក្នុងការដ្ឋានកំណែទម្រង់នេះ បានជំរុញឱ្យកំណែទម្រង់វិវឌ្ឍន៍ឈានមកកាន់ដំណាក់កាលថ្មីមួយទៀតនោះគឺ "ការកែទម្រង់សម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ"។ ជាមេរៀន បទពិសោធន៍ក្នុងរយៈពេលជិត១០ឆ្នាំកន្លងមកបានបង្ហាញថា នៅពេលដែលកំណែទម្រង់បានវិវឌ្ឍន៍ពីដំណាកាលមួយទៅកាន់ដំណាក់កាលថ្មីមួយទៀត បញ្ហាប្រឈមថ្មីៗប្រាកដជាលេចឡើង ដូចដែលអង្គសន្និបាតបានធ្វើការកត់សម្គាល់តាមរយៈរបាយការណ៍ បទអន្តរាគមន៍ និងការពិភាក្សានានារយៈពេលមួយថ្ងៃកន្លះកន្លងមកនេះ។

ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានា អង្គសន្និបាតបានប្តេជ្ញាចិត្តអនុវត្តតាមកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងផែនការអនុវត្ត៣ឆ្នាំដំបូងនៃកម្មវិធីជាតិ ដែលជាតម្រូវការជាអាទិភាពក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងរយៈពេលវែង ដើម្បីជំរុញដំណើរការកំណែទម្រង់នៅថ្នាក់ក្រោមជាតិឱ្យប្រព្រឹត្តទៅស្របតាមជំហាន និងដំណាក់កាល ទៅតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ពិសេសជាងនេះទៀត **សម្តេចនាយករដ្ឋមន្ត្រី** ផ្ទាល់តែងបានផ្តល់នូវការដឹកនាំ ណែនាំប្រកបដោយគតិបណ្ឌិត និងជាប្រចាំដល់យើងខ្ញុំ ចាប់តាំងពីដំណាក់កាលដំបូងៗនៃការអនុវត្តគោលនយោបាយកំណែទម្រង់ដែលមានភាពរសើប និងស្មុគស្មាញនេះ។

ថ្ងៃនេះ អង្គសន្និបាតទាំងមូលមានសេចក្តីរំភើបឥតឧបមា ដោយបានទទួលវត្តមានដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបិទអង្គសន្និបាតនេះ ដើម្បីបានត្រង់ត្រាប់ទទួលយកនូវអនុសាសន៍ដឹកនាំថ្មីៗថែមទៀតរបស់**សម្តេច** ក្នុងការលើកកម្ពស់ការអនុវត្តភារកិច្ចរៀងៗខ្លួន ក្នុងដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការដ៏មានសារៈសំខាន់នេះ ។

ក្នុងនាមអង្គសន្និបាតទាំងមូល ខ្ញុំសូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាមានមតិសំណេះសំណាល និងថ្លែងសុន្ទរកថាបិទអង្គសន្និបាត ព្រមទាំងសូមអនុញ្ញាតប្រសិទ្ធពរជ័យជាថ្មីម្តងទៀតជូន**សម្តេច** សូមប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមគោរពអញ្ជើញសម្តេច !**